# ច្បាប់

# ស្តីពី

# កិច្ចការពារបរិស្ថាន

# និង

# ការគ្រប់គ្រងធនធានធម្មជាតិ

# ព្រះរាជក្រម

នស.រកម.១២៩៦.៣៦

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន**

**រាជហរិវង្សឧភតោសុជាតិ វិសុទ្ធិពង្សអគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជបរមនាថបរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាក្រមលេខ នស.រកម.០១៩៦.២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ វិច្ឆិកា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅ :

- ការពារ លើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល

- វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គំរោងដែលបានស្នើឡើង

- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា

- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

## ជំពូកទី ២

## ផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់

**មាត្រា ២.-**

ផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ ត្រូវសំរេចដោយរាជរដ្ឋាភិបាល និងក្រសួងបរិស្ថានដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣.-**

ផែនការបរិស្ថានជាតិជាផែនការសំរាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរសំរាប់អនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ផែនការបរិស្ថានជាតិត្រូវ :

-កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

-លើកឡើងពីវិធានការសំរាប់ធានាការគ្រប់គ្រងបរិស្ថាន ។

**មាត្រា ៤.-**

ផែនការបរិស្ថានតំបន់ ត្រូវអនុលោមតាមផែនការបរិស្ថានជាតិ ។ ផែនការបរិស្ថានតំបន់ត្រូវ :

-កំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៃតំបន់នីមួយៗ ។

-លើកឡើង ពីវិធានការសំរាប់ធានាការគ្រប់គ្រងបរិស្ថាននៃតំបន់នោះ ។

**មាត្រា ៥.-**

ផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ត្រូវពិនិត្យ និងកែសំរួលយ៉ាងយូរមួយដងក្នុងរយៈពេលប្រាំឆ្នាំ ។

## ជំពូកទី ៣

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ៦.-**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ប្រភេទ និងទំហំគំរោង និងសកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## ការគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា ៨.-**

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ីរ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ ។

តំបន់ការពារធនធានធម្មជាតិមានជាអាទិ៍ ឧទ្យានជាតិ ជំរកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើន

យ៉ាង ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

**មាត្រា ៩.–**

ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ និងផ្តល់យោបល់ជូនក្រសួងពាក់ព័ន្ធ ដើម្បីធានាអោយធនធានធម្មជាតិដូចមានចែងក្នុងមាត្រា ៨ ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផលប្រកបដោយនិរន្តរភាព និងស្ថិតស្ថេរ ។

**មាត្រា ១០.–**

មុនពេលចេញសេចក្តីសំរេចនានា ឬធ្វើសកម្មភាពផ្សេងៗ ទាក់ទិនដល់ការអភិរក្ស ការអភិវឌ្ឍន៍ ឬការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ ក្រសួងពាក់ព័ន្ធត្រូវពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថានអំពីនិរន្តរភាព និងភាពស្ថិតស្ថេរនៃធនធានធម្មជាតិ ។

**មាត្រា ១១.–**

ក្រសួងបរិស្ថានត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងពាក់ព័ន្ធ នៅពេលណាដែលក្រសួងបរិស្ថានពិនិត្យឃើញថា ធនធានធម្មជាតិមិនមានការអភិរក្ស ការអភិវឌ្ឍន៍ ឬការគ្រប់គ្រងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរទេនោះ ។

## ជំពូកទី ៥

## កិច្ចការពារបរិស្ថាន

**មាត្រា ១២.–**

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពី :

-ប្រភព ប្រភេទ និងបរិមាណនៃសារធាតុបំពុល និងសំណល់ដែលបាននាំចូល បង្កើតឡើង ដឹកជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ដី ឬលើដី

-ប្រភព ប្រភេទ និងបរិមាណនៃសារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ដែលបាននាំចូល ផលិត ដឹកជញ្ជូន រក្សាទុក ប្រើប្រាស់ បង្កើតឡើង បានប្រព្រឹត្តកម្ម កែច្នៃឡើងវិញ បោះបង់ចោល ឬដែលបានបញ្ចេញចោលទៅក្នុងអាកាស ទឹក ឬទៅក្នុងដី ឬលើដី

-ប្រភព ប្រភេទ និងទំហំនៃការរំខានដោយសម្លេង និងរំញ័រ ។

**មាត្រា ១៣.–**

ការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុលអាកាស ទឹក ដី ការរំខាន ដោយសម្លេង និងរំញ័រព្រមទាំងសំណល់ សារធាតុពុល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៦

## ការត្រួតពិនិត្យ កំណត់ត្រា អធិការកិច្ច

### មាត្រា ១៤.-

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីកំណត់ឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងរោងចក្រ ប្រភពបំពុល តំបន់ឧស្សាហកម្ម ឬតំបន់មានសកម្មភាពអភិវឌ្ឍន៍ធនធានធម្មជាតិនានា :

-តម្លើង ឬប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ

-ផ្តល់គំរូតាង

-រៀបចំ ឬរក្សាទុក និងផ្ញើជូនពិនិត្យនូវកំណត់ត្រា និងរបាយការណ៍នានា ។

### មាត្រា ១៥.-

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន និងក្នុងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ អាចចូលធ្វើអធិការកិច្ចក្នុងតំបន់ ទីក្នុងបរិវេណ អាគារលើ ឬក្នុងមធ្យោបាយដឹកជញ្ជូន ឬទីកន្លែងណាមួយ ។ល។ ក្នុងករណីដែលក្រសួងបរិស្ថានពិនិត្យឃើញថាប្រភពនោះធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពបរិស្ថាន ។

មន្ត្រីអធិការកិច្ចរបស់ក្រសួងបរិស្ថាន និងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅមុនពេលធ្វើអធិការកិច្ច ។

នៅពេលធ្វើអធិការកិច្ច កាលណាពិនិត្យឃើញថាមានបទល្មើសព្រហ្មទណ្ឌកើតឡើង នោះមន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់ ។

នីតិវិធីនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៧

## ការចូលរួមរបស់សាធារណជន និងការស្រង់យកពត៌មាន

### មាត្រា ១៦.-

ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវពត៌មានពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

### មាត្រា១៧

បែបបទនៃការចូលរួមរបស់សាធារណជន និងការស្រង់យកពត៌មានក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

### មាត្រា ១៨.-

ពត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិ ត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមករវាងក្រសួងបរិស្ថាន និងក្រសួងនានា ។

## ជំពូកទី ៨
## មូលនិធិទាយជូទានបរិស្ថាន

**មាត្រា ១៩.-**

ត្រូវបង្កើតគណនីពិសេសរបស់រតនាគារជាតណនីមូលនិធិទាយជូទានបរិស្ថាន សំរាប់ឱ្យក្រសួងបរិស្ថានយកទៅចាត់ចែងក្នុងកិច្ចការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជូទានបរិស្ថាន ដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់អង្គការអន្តរជាតិនានា អំណោយពីសប្បុរជន អំណោយពីអង្គការក្រៅរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិដើម្បីផ្តល់អោយគណនីពិសេសខាងលើ ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ២០.-**

ចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើសនឹងការកំណត់របស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ក្រសួង បរិស្ថានត្រូវចេញបញ្ជាជាលាយល័ក្ខណ៍អក្សរតម្រូវឱ្យ :

-កែប្រែសកម្មភាពល្មើសជាបន្ទាន់ ឬក្នុងរយៈពេលណាមួយជាក់លាក់ ឬ

-ផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ឬ

-លុបបំបាត់ការបំពុលជាបន្ទាន់ ។

**មាត្រា ២១.-**

បុគ្គលណាមិនអនុញ្ញាត ឬរារាំងមិនឱ្យមន្ត្រីអធិការកិច្ចចូលធ្វើការត្រួតពិនិត្យ ឬធ្វើអធិការកិច្ចលើទីតាំងដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៥ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីប្រាំសែនរៀល (៥០០.០០០រៀល) ដល់មួយលានរៀល (១.០០០.០០០រៀល) ។

ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល(១.០០០.០០០រៀល) ដល់ប្រាំលានរៀល (៥.០០០.០០០រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ៣ខែ ឬទោសទាំងពីរនេះ ។

បុគ្គលណាប្រព្រឹត្តល្មើស និងមាត្រា ២០ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី មួយលានរៀល (១.០០០_.០០០រៀល)ដល់ដប់លានរៀល(១០.០០០.០០០រៀល)។ ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីម្ភៃមួយលានរៀល(២១.០០០.០០០រៀល)ដល់សាមសិបលានរៀល(៣០.០០០.០០០រៀល)ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ២២.-**

បើការប្រព្រឹត្តល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ឬជីវិតមនុស្ស ដល់ទ្រព្យសម្បត្តិឯកជន ដល់ទ្រព្យសម្បត្តិសាធារណៈ ដល់បរិស្ថាន ដល់ធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លានរៀល (១.000.000រៀល) ដល់ហាសិបលានរៀល(៥0.000.000រៀល) ឬផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់ប្រាំឆ្នាំ ឬទោសទាំងពីរនេះ ។

បុគ្គលដែលប្រព្រឹត្តបទល្មើសត្រូវទទួលជុសជុលសងការខូចខាត និងសងជំងឺចិត្តថែមទៀត ។

**មាត្រា ២៣.-**

ក្នុងករណីដែលការប្រព្រឹត្តល្មើសបង្កឱ្យមានគ្រោះមហន្តរាយធ្ងន់ធ្ងរចំពោះសង្គមជាតិ តុលាការអាចនឹងយកកាលៈទេសៈទម្ងន់ទោស ទៅប្រកបផ្សំ និងបទល្មើសណាមួយខាងលើនេះដើម្បីផ្តន្ទាទោស ។

**មាត្រា ២៤.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

**មាត្រា ២៥.-**

ក្រសួងបរិស្ថាន ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិនៃមាត្រា ២0 ខាងលើចំពោះបុគ្គលណាដែលប្រព្រឹត្តល្មើស និងអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធ និងបទប្បញ្ញត្តិនៃច្បាប់នេះ ។

ក្នុងករណីរឹងទទឹង ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ២៦.~**

ក្រោយពេលច្បាប់នេះចូលជាធរមានរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ចំពោះសកម្មភាពដែលកំពុងដំណើរការបច្ចុប្បន្ន រាជរដ្ឋាភិបាលអាចពន្យារពេលការប្រតិបត្តិអនុក្រឹត្យ ដែលចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ តាមសំណើរបស់ក្រសួងបរិស្ថាន ។

ក្នុងការសម្រេចពន្យារពេលនេះត្រូវ :

-ថ្លឹងថ្លែងពីប្រភេទ និងទំហំនៃគ្រោះថ្នាក់ដល់សុខភាពមនុស្ស ដល់បរិស្ថាន និងដល់ធនធានធម្មជាតិ ដែលអាចកើតឡើងពីការពន្យារពេលនេះ

-ពិនិត្យទៅលើលទ្ធភាព មធ្យោបាយ បច្ចេកទេស និងហិរញ្ញវត្ថុរបស់សកម្មភាពដែលកំពុងដំណើរការនេះ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ២៧.~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**ព្រះហត្ថលេខា ហត្ថលេខា**

**នរោត្ត រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខ : ០១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**យិន សេរី**